*<u>សេចក្តីព្រាងបញ្ចប់</u>*

# វេទិកាសម្រាប់កិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍កម្ពុជាលើកទី៣

*វិមានរដ្ឋាភិបាល - ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា*

*រាជធានីភ្នំពេញ ថ្ងៃទី០២-០៣ ខែមិថុនា ឆ្នាំ២០១០*

## ប្រធានបទនៃវេទិកា

***ការសម្រេចឱ្យបានជោគជ័យ «យុទ្ធសាស្ត្រចតុកោណ ដើម្បីកំណើន ការងារ សមធម៌ និងប្រសិទ្ធភាព ដំណាក់កាលទី២» តាមរយៈការអនុវត្តន៍ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ បច្ចុប្បន្នកម្ម***

◎◎◎◎

**ថ្ងៃអង្គារ៍ ទី០១ ខែមិថុនា ឆ្នាំ២០១០**

ម៉ោង ១៩:០០ អាហារពេលល្ងាចសម្រាប់ប្រធានគណៈប្រតិភូ រៀបចំដោយរាជរដ្ឋាភិបាលកម្ពុជា នៅសណ្ឋាគារ **Le Royal**

**ថ្ងៃពុធ ទី០២ ខែមិថុនា ឆ្នាំ២០១០**

ម៉ោង ៧:៣០-៨:៣០ ចុះឈ្មោះ

ម៉ោង ៨:៣០-១០:០០ សុន្ទរកថាស្វាគមន៍ ឯកឧត្តម **ឧបនាយករដ្ឋមន្ត្រី គាត ឈន់** ប្រធានវេទិកា

ចំណាប់អារម្មណ៍របស់ប្រធានសម្របសម្រួលខាងដៃគូអភិវឌ្ឍន៍ (ធនាគារពិភពលោក)

សុន្ទរកថាគន្លឹះរបស់ **សម្តេច អគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា**

*<u>គោលបំណង</u> ÷ បញ្ជាក់ប្រធានបទសំខាន់នៃវេទិកាលើកទី៣ និងវឌ្ឍនភាពបន្ទាប់ពីវេទិកាលើកទី២ ព្រមទាំងកំណត់ក្របខ័ណ្ឌសម្រាប់ចំណុចគន្លឹះៗដែលត្រូវសម្រេចក្នុងវេទិកាលើកនេះ*

ម៉ោង ១០:០០-១០:៣០ សម្រាកពិសារភេសជ្ជៈ

ម៉ោង ១០:៣០-១២:០០ **<u>របៀបវារៈទី១</u> ៖ ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ- បច្ចុប្បន្នកម្ម**

*<u>គោលបំណង</u> ÷ ត្រួតពិនិត្យអំពីវឌ្ឍនភាពនៃការអនុវត្តផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ និងគោលដៅអភិវឌ្ឍន៍សហសវត្សរ៍កម្ពុជា កាលានុវត្តភាពនិងបញ្ហាប្រឈមដែលត្រូវដោះស្រាយក្នុងពេលអនុវត្តផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ បច្ចុប្បន្នកម្ម ។ ឯកភាពលើសកម្មភាពចាំបាច់ដើម្បីឈានទៅសម្រេចគោលដៅអភិវឌ្ឍន៍ជាតិ ។*

- សេចក្តីផ្តើមរបស់ប្រធានវេទិកា ៥ នាទី
- បទបង្ហាញរបស់ក្រសួងផែនការ ២០ នាទី
- បទបង្ហាញ តំណាងដៃគូអភិវឌ្ឍន៍ ១៥ នាទី
- ពិភាក្សា ៥០ នាទី

**<u>របៀបវារៈទី២</u> ៖ អាទិភាពជាយុទ្ធសាស្រ្តសម្រាប់កិច្ចអភិវឌ្ឍន៍ក្រោយពីកលិយុគហិរញ្ញវត្ថុ និងសេដ្ឋកិច្ចពិភពលោក**

- សេចក្តីផ្តើមរបស់ប្រធានវេទិកា ៥ នាទី

ម៉ោង ១២:០៥-១២:៣០ ក- <u>ការគ្រប់គ្រងម៉ាក្រូសេដ្ឋកិច្ច</u>

*<u>គោលបំណង</u> ÷ ពិនិត្យវឌ្ឍនភាពសម្រេចបានកន្លងមក ទស្សនវិស័យនិងវិធានការកម្រិតគោលនយោបាយសម្រាប់អនុវត្តក្នុងឆ្នាំ២០១០ ដើម្បីធានាស្ថេរភាពម៉ាក្រូសេដ្ឋកិច្ច ។ ពិនិត្យតួនាទីរបស់ផ្នែកឯកជន និងឯកភាពលើសកម្មភាពគន្លឹះៗ ដើម្បីជម្រុញមូលដ្ឋានទូលំទូលាយនៃកំណើនសេដ្ឋកិច្ច ។*

- បទបង្ហាញរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ តំណាងគណៈកម្មាធិការ គោលនយោបាយសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ១៥ នាទី
- បទបង្ហាញរបស់តំណាងដៃគូអភិវឌ្ឍន៍ ១០ នាទី

ម៉ោង ១២:៣០-១៤:០០ សម្រាកពិសារអាហារថ្ងៃត្រង់នៅក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា

**<u>របៀបវារៈទី២</u> (បន្ត) ៖ អាទិភាពជាយុទ្ធសាស្រ្តសម្រាប់កិច្ចអភិវឌ្ឍន៍ក្រោយពីកលិយុគហិរញ្ញវត្ថុ និងសេដ្ឋកិច្ចពិភពលោក**

ម៉ោង ១៤:០០-១៤:៣០ ក- <u>ការគ្រប់គ្រងម៉ាក្រូសេដ្ឋកិច្ច</u> (បន្ត)

- ពិភាក្សា ៣០ នាទី

ម៉ោង ១៤:៣០-១៥:៣០ ខ- <u>ការលើកកំពស់ផលិតភាពកសិកម្ម និងពិពិធកម្ម</u>

*<u>គោលបំណង</u> : ពិនិត្យវឌ្ឍនភាព ទស្សនវិស័យ និងវិធានការគន្លឹះសម្រាប់អនុវត្តក្នុងឆ្នាំ២០១០ សំដៅលើកកំពស់ផលិតភាពកសិកម្ម និងពិពិធកម្មវិស័យកសិកម្ម ។*

- បទបង្ហាញរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ១៥ នាទី
- បទបង្ហាញរបស់តំណាងដៃគូអភិវឌ្ឍន៍ ១០ នាទី
- ពិភាក្សា ៣៥ នាទី

ម៉ោង ១៥:៣០-១៦:០០ សម្រាក

ម៉ោង ១៦:០០-១៧:០០ គ- <u>ការគាំពារសង្គមសម្រាប់ជនក្រីក្រ និងជនងាយរងគ្រោះ</u>

*<u>គោលបំណង</u> : ពិនិត្យវឌ្ឍនភាពនៃការអនុវត្តន៍វិធានការពង្រឹងការគាំពារសង្គមសម្រាប់អ្នកក្រីក្រនិងក្រុមងាយរងគ្រោះ និងឯកភាពលើសកម្មភាពគន្លឹះដើម្បីឈានទៅរៀបចំប្រព័ន្ធគាំពារសង្គមមួយមានលក្ខណៈគ្រប់ជ្រុងជ្រោយ*

- បទបង្ហាញរបស់ក្រុមប្រឹក្សាស្តារ អភិវឌ្ឍន៍វិស័យកសិកម្ម និងជនបទ ១៥ នាទី
- បទបង្ហាញរបស់តំណាងដៃគូអភិវឌ្ឍន៍ ១០ នាទី
- ពិភាក្សា ៣៥ នាទី

**<u>របៀបវារៈទី៣</u> ៖ <u>កម្មវិធីកំណែទម្រង់អាទិភាពដើម្បីសម្រេចនូវផែនការយុទ្ធសាស្រ្តអភិវឌ្ឍន៍ជាតិ- បច្ចុប្បន្នកម្ម</u>**

ម៉ោង ១៧:០៥-១៨:០០ ក - ការអភិវឌ្ឍន៍តាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ

*<u>គោលបំណង</u> : ពិនិត្យវឌ្ឍនភាពនិងបញ្ហាប្រឈមក្នុងការអនុវត្តន៍កំណែទម្រង់វិមជ្ឈការនិងវិសហមជ្ឈការ - ការអនុវត្តកម្មវិធីជាតិរយៈ ពេល១០ឆ្នាំ ដើម្បីធានាសង្គតិភាព និងលទ្ធផលរបស់កម្មវិធីជាតិនៅតាមវិស័យ និងនៅតាមថ្នាក់គ្រប់គ្រងរដ្ឋបាលរបស់រាជរដ្ឋាភិបាល*

- សេចក្តីផ្តើមរបស់ប្រធានវេទិកា ៥ នាទី
- បទបង្ហាញរបស់ក្រសួងមហាផ្ទៃ តំណាងឱ្យគណៈកម្មាធិការជាតិដឹកនាំការអភិវឌ្ឍន៍តាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (គ.ជ.អ.ប) ១៥ នាទី
- បទបង្ហាញរបស់តំណាងដៃគូអភិវឌ្ឍន៍ ១០ នាទី
- ពិភាក្សា ៣០ នាទី

**ថ្ងៃព្រហស្បតិ៍ ទី០៣ ខែមិថុនា ឆ្នាំ២០១០**

**<u>របៀបវារៈទី៣</u> (បន្ត) : <u>កម្មវិធីកែទម្រង់ជាអាទិភាពដើម្បីសម្រេចនូវផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ- បច្ចុប្បន្នកម្ម</u>**

ម៉ោង ០៩:០០-១០:០០ គ- <u>ប្រសិទ្ធភាពហិរញ្ញប្បទានសហប្រតិបត្តិការនៅកម្ពុជា- វឌ្ឍនភាព បញ្ហាប្រឈម និងអនុសាសន៍</u>

*<u>គោលបំណង</u> : ពិនិត្យវឌ្ឍនភាពនៃការលើកកំពស់ប្រសិទ្ធភាពហិរញ្ញប្បទានសហប្រតិបត្តិការ កំណត់អាទិភាពដើម្បីពន្លឿនល្បឿននៃការអនុវត្តន៍ដើម្បីសម្រេចគោលដៅអភិវឌ្ឍន៍សហសវត្សរ៍របស់កម្ពុជា*

- បទបង្ហាញរបស់ ក.អ.ក/គ.ជ.នា ១៥ នាទី
- បទបង្ហាញរបស់តំណាងដៃគូអភិវឌ្ឍន៍ ១០ នាទី
- ពិភាក្សា ៣៥ នាទី

ម៉ោង ១០:០០-១០:៣០ **<u>របៀបវារៈទី៤</u> : ការអនុមតិសូចនាករតាមដានរួមគ្នា ឆ្នាំ២០១០**

*<u>គោលបំណង</u> : ភាពជាដៃគូក្នុងកិច្ចអភិវឌ្ឍន៍ឈរលើការពិភាក្សា និងការឯកភាពកន្លងមក ដោយផ្តោតលើលទ្ធផល និងដោយផ្អែកតាមគោលការណ៍គណនេយ្យភាពទ្វេទិស*

- បទបង្ហាញរបស់ ក.អ.ក/គ.ជ.នា ១០ នាទី
- បទបង្ហាញរបស់តំណាងដៃគូអភិវឌ្ឍន៍ ១០ នាទី
- ពិភាក្សា ១០ នាទី

ម៉ោង ១០:៣០-១១:០០ សម្រាក

**<u>របៀបវារៈទី៣</u> (បន្ត) : <u>កម្មវិធីកែទម្រង់ជាអាទិភាពដើម្បីសម្រេចនូវផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ- បច្ចុប្បន្នកម្ម</u>**

ម៉ោង ១១:០០-១២:០០ ខ- <u>កំណែទម្រង់រដ្ឋបាលសាធារណៈ ច្បាប់និងតុលាការ និងច្បាប់ប្រឆាំងនឹងអំពើពុករលួយ</u>

*<u>គោលបំណង</u> : ឯកភាពលើទិសដៅជាយុទ្ធសាស្ត្រក្នុងការកែទម្រង់រដ្ឋបាលច្បាប់ និងតុលាការ និងការតម្រឹមធនធានរបស់ដៃគូអភិវឌ្ឍន៍ ។*

- បទបង្ហាញរបស់ក្រុមប្រឹក្សាកំណែទម្រង់រដ្ឋបាលសាធារណៈ ២០ នាទី
- បទបង្ហាញរបស់តំណាងដៃគូអភិវឌ្ឍន៍ ១០ នាទី
- ពិភាក្សា ៣០នាទី

ម៉ោង ១២:០០-១២:៣០ **<u>របៀបវារៈទី៥</u> : ក្របខ័ណ្ឌហិរញ្ញប្បទានណែនាំពហុឆ្នាំ**

- បទបង្ហាញរបស់ឯកឧត្តម ឧបនាយករដ្ឋមន្ត្រី **គាត ឈន់** រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងជាអនុប្រធានទី១ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ១០ នាទី
- ដៃគូអភិវឌ្ឍន៍បញ្ជាក់ការគាំទ្រសរុបសម្រាប់ឆ្នាំ២០១០-២០១២ ១០ នាទី

ម៉ោង ១២:៣០-១៤:៣០ សម្រាកពិសារភោជនាហារថ្ងៃត្រង់នៅក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា

ម៉ោង ១៤:៣០-១៥:៣០ **របៀបវារៈទី៦ : ពិធីបិទវេទិកា**

- សង្ខេបលទ្ធផលនៃវេទិកា ឯកឧត្តម **អូន ព័ន្ធមុនីរ័ត្ន** រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី ប្រធានឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ និងប្រធានបម្រុងវេទិកា ២០ នាទី
- កំណត់សំគាល់របស់ប្រធានសម្របសម្រួលដៃគូអភិវឌ្ឍន៍ (ធនាគារពិភពលោក) ១៥ នាទី
- សុន្ទរកថាបិទវេទិការបស់ឯកឧត្តម ឧបនាយករដ្ឋមន្ត្រី **គាត ឈន់** ប្រធានវេទិកា ១០ នាទី

ម៉ោង ១៥:៣០ សន្និសីទសារព័ត៌មាន